ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១០ លេខ ២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ




Work Activities

ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧



# មាតិកា


ល.រ បរិយាយ — លេខទំព័រ

I- កិច្ចប្រជុំជំនាញបច្ចេកទេស

- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសហប្រតិ-បត្តិការកាយរឹទ្ធិក្រោមឱវាទអគ្គនាយកដ្ឋានយុវជន នៃក្រសួងអប់រំ យុវជន និងកីឡា ១-២

II- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមករា ឆ្នាំ២០១៧ ៣-១០

III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧ ១១-១៧

# សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសហប្រតិបត្តិការកាយវប្បកម្មនិងកីឡា ក្រោមឱវាទអគ្គនាយកដ្ឋានយុវជននៃក្រសួងអប់រំ យុវជន និងកីឡា

កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ផៃ សុខខេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសហប្រតិបត្តិការកាយវប្បកម្ម ក្រោមឱវាទអគ្គនាយកដ្ឋានយុវជននៃក្រសួងអប់រំ យុវជន និងកីឡា** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអប់រំ យុវជន និងកីឡា។



អនុវត្តតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយរបស់រាជរដ្ឋាភិបាលនិងធម្មនុញ្ញកាយវប្បកម្ម ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសហប្រតិបត្តិការកាយវប្បកម្ម សំដៅពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការការងារកាយវប្បកម្មលើឆាកអន្តរជាតិនិងពង្រឹងចលនាកាយវប្បកម្មកម្ពុជា ឲ្យស្របទៅនឹងកម្មវិធីកំណែទម្រង់វិស័យអប់រំ ដែលបានដាក់ចេញក្នុងនីតិកាលទី៥ នៃរដ្ឋសភា។ ការបង្កើតនាយកដ្ឋានសហប្រតិបត្តិការកាយវប្បកម្ម ត្រូវបានធ្វើឡើងក្នុងគោលបំណងគ្រប់គ្រង ដឹកនាំកិច្ចការកាយវប្បកម្មនៅតាមគ្រឹះស្ថានសិក្សានានា ពង្រឹងនិងពង្រីកសកម្មភាពចូលរួមរបស់សិក្សានុសិស្សតាមប្រព័ន្ធកាយវប្បកម្ម ដើម្បីទទួលបានជំនាញបំណិនជីវិត អភិវឌ្ឍសមត្ថភាពជំនាញទន់ និងបង្កើនសមត្ថភាពការសិក្សារៀនសូត្រ និងអកប្បកិរិយាសមស្របក្នុងការបណ្តុះបណ្តាលធនធានមនុស្សឲ្យក្លាយទៅជាមូលធនមនុស្ស ដើម្បីសម្រេចចក្ខុវិស័យឆ្នាំ២០៣០ ដែលរាជរដ្ឋាភិបាល ចង់ប្រែក្លាយប្រទេសកម្ពុជាជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ និងប្រែក្លាយទៅជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ ខាងមុខ។

ម្យ៉ាងវិញទៀត ការបង្កើតនាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិនេះ គឺស្របតាមការដែលរាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូន ក្រសួងអប់រំ យុវជន និងកីឡា ទទួលខុសលើការងារកាយរឹទ្ធិ។ នាយកដ្ឋានថ្មីនេះមានតួនាទីភារកិច្ចដូចបានកំណត់នៅក្នុងមាត្រា៤ នៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិ(១)។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ៕




(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិក្រោមឱវាទអគ្គនាយកដ្ឋានយុវជននៃក្រសួងអប់រំ យុវជន និងកីឡា។

# II- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមករា ឆ្នាំ២០១៧



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា **ប្រចាំខែមករា ឆ្នាំ២០១៧** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែមករាឆ្នាំ២០១៧សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៣% ធៀបនឹងខែមុន និងកើនឡើង៤,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ម្ហូបអាហារ: | +៦,៧% | បន្លែ: | +១៥,៧% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +៣,៧% | ត្រីស្រស់: | +១០,១% |
| សំលៀកបំពាក់ និងស្បែកជើង: | +៣,៦% | សាច់មាន់: | +៨,៤% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +៣,៣% | ផ្លែឈើ: | +៦,២% |
| ភោជនីយដ្ឋាន: | +៣,៣% | សាច់គោ: | +៦,១% |
| ការកំសាន្ត និងវប្បធម៌: | +៣,១% | សាច់ជ្រូក: | +៤,៦% |
| ការដឹកជញ្ជូន: | +២,៦% | ប្រេងសាំង: | +៤,៥% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +២,៦% | ប្រេងម៉ាស៊ូត: | +២,៤% |
| សុខាភិបាល: | +២,១% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៥–២០១៧

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ P | មីនា P | មេសា P | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៣,៩% | ៣,៧% | ៣,៦% | | | | | | | | | |
| | មុន | ០,៣% | -០,១% | -០,៤% | -០,១% | | | | | | | | | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,២% | ០% | -០,២% | ០,២% | |

P: តួលេខខែកុម្ភៈ មីនា និងមេសា ឆ្នាំ២០១៧ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | មករា ២០១៧ | ធ្នូ២០១៦ | មករា ២០១៦ | *ប្រភេទ* | មករា ២០១៧ | ធ្នូ២០១៦ | មករា ២០១៦ |
|---|---|---|---|---|---|---|---|
| **រ/ដុល្លារ** | ៤០៣៥រ/១$ | ៤០៣៧រ/១$ | ៤០២៧រ/១$ | **បាត/ដុល្លារ** | ៣៥,២០បាត/១$ | ៣៥,៨៣បាត/១$ | ៣២,៣៧បាត/១$ |
| **រ/បាត** | ១១៥រ/១បាត | ១១៣រ/១បាត | ១២៤រ/១បាត | **ដុង/ដុល្លារ** | ២២៥៩០ដុង/១$ | ២២១៩៣ដុង/១$ | ២១៣៣៥ដុង/១$ |
| **រ/ដុង** | ០,១៧៩រ/១ដុង | ០,១៨២រ/១ដុង | ០,១៨៩រ/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែមករា ឆ្នាំ២០១៧ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១០៥២,២ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២៦៣ លានដុល្លារ (*មធ្យមប្រចាំខែ ៧៩% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន១០៥២,២ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២៦៣លានដុល្លារ( *មធ្យមប្រចាំខែ ៨១% នៃផែនការ*) និងមិនមានចំណូលមូលធនទេ(តាមតួលេខរតនាគារជាតិ)។

➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិថយចុះ៤០.២% ប៉ុន្តែកើនឡើង២២,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១០០៧,៣ប៊ីលានរៀល ថយចុះ៧,៦%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២៦,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខរតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៥ –២០១៧

(ប៊ីលានរៀល)




✓ចំណូលមិនមែនសារពើពន្ធ មានចំនួន៤៤,៨ប៊ីលានរៀល ថយចុះ៨៩,១%ធៀបនឹងខែមុន និងថយចុះ២៥,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខរតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: -៧,៨% | (-៧,២%) | ➢កាស៊ីណូ :-៦០,១% | -៥០,៤% |
| (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | | ➢អាជ្ញាបណ្ណក្នុងស្រុក : -៩៩,៧% | (-១៨,៥%) |
| ➢ ចំណូលពន្ធដារ: +១៨១,៣% | (+១៧៣,៧%) | ➢កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ :+ | (-) |
| (អគ្គនាយកដ្ឋានពន្ធដារ) | | ➢ នេសាទ:+២៦៨,៥% | (+៣៩៥,២%) |
| | | ➢សម្បទានរ៉ែ: -៩១,៥% | ( ) |
| | | ➢ អាកាសចរណ៍ស៊ីវិល: -៩០.៨% | (-២៧,៣%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: -៩៩,៩% | (+១១០,៦%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ):-៤៨.៦% | (-១៧,៧%) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ៤៨២,៤ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១២០,៦ លានដុល្លារ( *មធ្យមប្រចាំខែ ៣៦% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន ៤៤៥,៦ប៊ីលានរៀល ( *មធ្យមប្រចាំខែ ៤១% នៃផែនការ*) និងចំណាយមូលធនមានចំនួន៣៦,៨ប៊ីលានរៀល( តាមតួលេខ រតនាគារជាតិ )។

➤ចំណាយថវិកាជាតិថយចុះ៨១,៧%ធៀបនឹងខែមុននិងថយចុះ២៥,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ៧៨,៩%ធៀបនឹងខែមុននិងថយចុះ២៣,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៥–២០១៧




**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន ៥៦៩,៨ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១៤២,៥ លានដុល្លារ ( តួលេខរតនាគារជាតិ )។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមករាឆ្នាំ២០១៧មានលក្ខណៈដូចខាងក្រោម:

➤រូបិយវត្ថុ$M_2$ មានចំនួន៥៨៨៥២ប៊ីលានរៀល កើនឡើង២,១%ធៀបនឹងខែមុន និងកើនឡើង១៨,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង $M_2$** ក្នុងខែនេះ ជារួម បណ្ដាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ៣,២% ប្រាក់បញ្ញើចរន្ត ៨% និងប្រាក់បញ្ញើជារូបិយបណ្ណ២,២%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែមករាឆ្នាំ២០១៧




➤ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៦,៧% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣,៣% នៃរូបិយវត្ថុ $M_2$ ។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៧

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៦,៧% | | | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៣% | | | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែមករា២០១៧: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន



➢ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៦៧៨៣លានដុល្លារ កើនឡើង២,២%ធៀបនឹងខែមុន និងកើនឡើង៣៥,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ២០៥៦១ ប៊ីលានរៀលកើនឡើង២,៣%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២៨,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *មករា២០១៧* | *ធ្នូ២០១៦* | *មករា២០១៦* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ ជារៀល | ៥៨២២៧ | ៥៧០៣៥ | ៥០០៣១<br>៦៣២ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | | ១២៦៤៣ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៨៥% | ៦,៩១% | ៦,៦២% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,២៤% | ១៧,៣៥% | ១៦,៣១% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៤% | ៤,៤៤% | ៤,៤៦% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៩២% | ១១,៩០% | ១១,៨២% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថកសិករ | | ២៣,៤% | ៣១,២% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | | ២៨,៨% | ២៩,៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | | ២២,៨% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែមករាឆ្នាំ២០១៧ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៥៣,៤ពាន់តោន ថយចុះ៥៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៥៧៤GWHមានការកើនឡើង២,០%ធៀបនឹងខែមុន និងកើនឡើង៩,០%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៤០,៧GWHមានការថយចុះ៤៧%ធៀបនឹងខែមុន និងថយចុះ២៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៣៥៧,៥GWHមានការកើនឡើង១០%ធៀបនឹងខែមុន និងមានការកើនឡើង៣២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៥២៦,៥លានដុល្លារមានការកើនឡើង១០% ធៀបនឹងខែមុន និងកើនឡើង២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន—មករា២០១៧* | *ចំនួន—ធ្នូ២០១៦* | *ចំនួន—មករា២០១៦* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៤ | ១៣ | ១៤ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៥៨៣ | ១៥៧៩ | ១៤៦៤ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៤ | ១២ | ២៥ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ២០ | ២១ | ១៨ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៣២៥ពាន់ម៉ែត្រការ៉េ ថយចុះ៥៥%ធៀបនឹងខែមុន និងថយចុះ៥៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង១៥៦លានដុល្លារថយចុះ៥២%ធៀបនឹងខែមុន និងថយចុះ៦០%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម៉ែត្រការ៉េ —មករា២០១៧ | ពាន់ម៉ែត្រការ៉េ —ធ្នូ២០១៦ | ពាន់ម៉ែត្រការ៉េ —មករា២០១៦ |
|---|---|---|---|
| ▪ លំនៅឋាន | ២០៩,២ | ៦៦៤,៦ | ២៧៨,៨ |
| ▪ ឧស្សាហកម្ម | ១៥,០ | ៦,៨ | ១២៥,២ |
| ▪ពាណិជ្ជកម្ម | ៧១,៧ | ៣០,៧ | ២៧៩ |
| ▪ ទេសចរណ៍ | ២៤,៣ | ៤,៦ | ៧,៩ |
| ▪ផ្សេងៗ | ០,០ | ០,១ | ០,០ |
| អនុញ្ញាតសរុប | ៣២៥ | ៧១៣,៥ | ៦៩៣,៥ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅដ្ឋាន៦៤,៤% និងពាណិជ្ជកម្ម២២%នៃផ្ទៃក្រឡាសរុប។

➢**ការងារ**

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់—មករា ២០១៧ | នាក់—ធ្នូ ២០១៦ | នាក់—មករា ២០១៦ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១៦៦១ | ១០៤១ | ៧៣៧ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២៤៩១០ | ២៤៤៦១ | ៥៨៦៦ |
| អ្នកទទួលបានការងារក្នុងប្រទេស | ២៣២០០ | ២០៨៤៥ | ៤៧៨០ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៧១០ | ៣៦១៦ | ១០៨៦ |

➢**វិនិយោគ**

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | មករា២០១៧ | ធ្នូ២០១៦ | មករា២០១៦ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៤៤ | ៦៥៦,៦ | ១៦៨,៥ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៨ | ៣០០,៦ | ២,២ |
| វិស័យឧស្សាហកម្ម (ក្នុងរង្វង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ២៧ (១,០) | ២៣៦,២ (១៨៨,៤) | ៩៦,៩ (៣៤,៦) |
| វិស័យទេសចរណ៍ | ៤ | ១៦,៣ | ៦៩,៤ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៤ | ១០៣,៥ | ០,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១០ | ៣៨ | ១៦ |
| បង្កើតការងារ (ពាន់នាក់) | ៤ | ៤៤ | ១០,៧ |

➢**សេវាកម្ម**

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន—មករា២០១៧ | ចំនួន—ធ្នូ២០១៦ | ចំនួន—មករា២០១៦ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣៤១ | ២៩៩ | ១៧៩ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១ | ២ | ០ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៥២៦ | ៣៦២ | ១៣៦ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៨៨០,៨ពាន់តោនថយចុះ៨%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៤%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-១២% | (-១៥%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:+១១០% | (-៨៦%) |
| ▪ កំពង់ផែកំពង់សោម:-៩% | (+១៧%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +១២% | (+១១១%) |

➢**ប្រៃសណីយ៍និងទូរគមនាគមន៍**

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៦ | -៣% | ៤% |
| ក្នុងនោះទទួល | ២,៤ | ៨% | ១១% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១២៤ | -១១% | ៣% |
| ក្នុងនោះទទួល | ៥៩,៥ | -៣% | ១៤% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២៥៥០,៥ | -៥% | -១៧% |
| ក្នុងនោះហៅចូល | ៧៥១ | -៥% | -១៧% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១០៣៦៥,៥ | ២២% | -៣២% |
| ក្នុងនោះហៅចូល | ១០៣០៣,០ | ២២% | -៣២% |

➢**ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍**

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២០,៥ | -១៩% | ៤៦% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៥០,១ | ៦% | ១៧% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៧៣៥,៧ | ៩% | ២០% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១២៣,១ | -៣,៥% | ១៤% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៥៣១,៩ | -១៣% | ១៤% |
| ✓ តាមផ្លូវអាកាស | ៣២៨,៦ | ៨% | ២០% |
| ✓ តាមផ្លូវគោក និងទឹក | ២០៣,៣ | -៣៤% | ៥% |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែមករា ឆ្នាំ២០១៧ មានចំនួន ៤៤៣២,៧ប៊ីលានរៀល (ស្មើនឹង១១០៨,២លានដុល្លារ ស.រ.អា.)ថយចុះ៦,៨%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៦,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ□ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -៣,២% | -៦,៧% | រថយន្តសរុប (ប៊ី.ល.រ) | +៥០,៨% | +៦២,១% |
| ប្រេងម៉ាស៊ូត | +៦,០% | -៩,៨% | រថយន្តសរុប (គ្រឿង) | -១៨,៥% | -១១,៦% |
| ឧស្ម័ន | -៦% | +៨,៤% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -៣,៤% | -៥,២% |

| | | | | | |
|---|---|---|---|---|---|
| អគ្គិសនីនាំចូល | +៣,០% | -៤% | ម៉ូតូ (គ្រឿង) | +២,៤% | -៣៣,៨% |
| ដែកសំណង់ | -៦,៧% | -១,៨% | អង្ករ | +៨% | -៩៥,៩% |
| ស៊ីម៉ង់ត៍ | -១៤,៣% | -២៤,៣% | ផ្លែឈើនិងបន្លែ | +២៣,៣% | +៥,៦% |
| គ្រឿងអេឡិចត្រូនិក | +៣,៦% | +៨៧,៥% | ជីនិងថ្នាំកសិកម្ម | -២៩% | -៤២,៩% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៩% | -០,២% |

➡ **ការនាំចេញ** ខែមករាឆ្នាំ២០១៧ មានចំនួន**៣២៦៩,៥**ប៊ីលានរៀល ស្មើនឹង**៨១៧**,៤លានដុល្លារ ស.រ.អា. (**៧៣,៧**% នៃការនាំចូល)ថយចុះ១៦,១%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៨,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| *ទំនិញ* | *%∆ធៀបនឹង ខែមុន* | *%∆ធៀបនឹងខែ ដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%∆ធៀបនឹង ខែមុន* | *%∆ធៀបនឹងខែដូច គ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៤១,៦% | -១៣,៥% | ផលិតផលនេសាទ | -៧០,៤% | -៥៩,៩% |
| វាយនភណ្ឌនិងស្បែកជើង | -១៣,៥% | +១២,៦% | កៅស៊ូ | +២,៣% | +៤០,៦% |
| អង្ករ | -២៧,៦% | -១៨,២% | | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមករាឆ្នាំ២០១៧នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃសាច់មាន់ស្រស់ | +០,៩% | +៨,៤% | — |
| ២ | ថ្លៃត្រីស្រស់ | +០,២% | +១០,១% | |
| ៣ | ថ្លៃបន្លែ | +០,៣% | +១៥,៧% | — |
| ៤ | ចំណូលពន្ធដារ | +១៨១,៣% | +១៧៣,៧% | តាមតួលេខអគ្គនាយកដ្ឋានពន្ធដារ ការកើនឡើងយ៉ាងច្រើនក្នុងខែមករា ដោយមកពីការបូកបញ្ចូលសល់ពីឆ្នាំ២០១៦ផង។ ធម្មតាកំណើនប្រចាំខែ ប្រហែល២៥%។ |
| ៥ | ចំណូលមិនមែនសារពើពន្ធ | -៨៦,៣% | -២៥,៧% | មានការថយចុះនៃចំណូល កាស៊ីណូ អជ្ញាបណ្ណក្នុងស្រុក អាករស្ពានទូត និងអាកាសចរណ៍ស៊ីវិល |
| ៥ | សំណង់អនុញ្ញាតឲ្យសាងសង់ | -៥៥% | -៥៣% | ជាចម្បងដោយសារការធ្លាក់ចុះនៃសំណង់ធំៗ |
| ៦ | ទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក. | -៩៣,៣% | -៧៤,០% | ជាចម្បងដោយសារការការធ្លាក់ចុះនៃវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស |

## ៧) សេចក្តីសន្និដ្ឋាន

១) សុខាភិបាល:

– សេវាសុខាភិបាលត្រូវបានលើកមកពិភាក្សាសារជាថ្មី។ ទោះជាសេវាសុខាភិបាលមានការរីកចម្រើនហើយក៏ដោយ ចំនុច ខ្វះខាតខ្លះជាការងារបុគ្គលក៏នៅមាន ដូចជាពត៌មានអំពីសេវាសម្ភពដែលមានករណីស្ត្រីត្រូវសម្រាលកូន ប៉ុន្តែមន្ទីពេទ្យឯកជនប្រកែកបើគ្មានប្រាក់សម្រាប់បង់។ ដូច្នេះ ការប្រើប្រាស់មូលនិធិសមធម៌សុខាភិបាលអាចនៅមិនទាន់បានផ្ជួតផ្ជាបនៅឡើយ។

– ថ្លៃសេវាសុខាភិបាលមានកម្រិតខ្ពស់ ឯគុណភាពមានកម្រិត និងខ្វះភាពទន់ភ្លន់ ការយកចិត្តទុកដាក់អតិថិជន ធ្វើឲ្យ វិស័យនេះបាត់បង់ការជឿទុកចិត្ត មិនអាចប្រកួតប្រជែងបានជាអន្តរជាតិ បណ្តាលឲ្យមានទេសចរសុខាភិបាលជាច្រើនចេញទៅប្រើសេវាពិនិត្យព្យាបាលនៅប្រទេសជិតខាង និងលំហូរចេញនៃថវិកាដ៏សន្ធឹកសន្ធាប់។

– តើអាចរៀបចំជាសមាគមនៃមន្ទីរពេទ្យឯកជន ដែលអាចជាដៃគូរដ្ឋាភិបាល ក្នុងការពង្រឹងសេវាសុខាភិបាលឯកជន អោយមានភាពកាន់តែប្រសើរឡើង។

– ការពង្រឹងការអនុវត្តក្រមសីលធម៌ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសេវាសុខាភិបាលឯកជន ការណែនាំនិងការផ្សព្វផ្សាយបទដ្ឋានគតិយុត្តចំពោះស្ថាប័នក្រោមបង្គាប់ អោយបានកាន់តែសកម្មថែមទៀត។

២) ការនាំចូលៈ

– អង្គប្រជុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងថា បន្លែផលិតក្នុងស្រុកមានសុវត្ថិភាពជាងបន្លែនាំចូល។ តែបន្លែនាំចូលមានចំនួនប្រហែលពាក់កណ្តាលនៃការប្រើប្រាស់សរុប ដែលមានតម្លៃថោក ធ្វើឲ្យបន្លែដែលដាំក្នុងស្រុកពិបាកប្រកួតប្រជែងហើយការលក់ដូរនៅលាយឡំជាមួយគ្នានៅឡើយ។ អង្គប្រជុំយល់ឃើញថា បើមានការរៀបចំទីផ្សារបោះដុំបន្លែឲ្យដាច់ពីគ្នារវាងបន្លែនាំចូល និងបន្លែដាំក្នុងស្រុក អាចជួយឲ្យអតិថិជនធ្វើអត្តសញ្ញាណកម្មបាន នាំអោយតម្រូវការបន្លែ ផលិតក្នុងស្រុកអាចកើនឡើង ហើយតម្លៃបន្លែផលិតក្នុងស្រុកក៏អាចរក្សាបានដែរ។

– វិធីបែបនេះក៏អាចធ្វើចំពោះទីផ្សារផ្សេងទៀត ដូចជា សាច់ និងអង្ករ។ អង្ករនាំចូលពីប្រទេសណា ត្រូវតែមានផ្លាកសញ្ញាថាជាអង្ករផលិតនៅប្រទេសនោះ កុំឲ្យមានការភន្តច្រលំពីសំណាក់អ្នកប្រើប្រាស់ ដែលនាំឲ្យអ្នកនាំចូលកេងចំណេញពីការខ្វះព័ត៌មានដល់អតិថិជន។

៣) ការពុះដីឡូលក់ដោយម្ចាស់ដីឡូធំៗ អាចប្រឈមនឹងបញ្ហាចម្រូងចម្រាសនាពេលក្រោយ ព្រោះថាការពុះឡូនោះ អាចមិនស្របតាមបទដ្ឋានបច្ចេកទេស ឬមិនស្របតាមប្លង់មេនៃអាជ្ញាធរដែនដីក្នុងការអភិវឌ្ឍតំបន់នោះ៕

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០២/១៧<br>**ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិត សាកលវិទ្យាល័យជាតិគ្រប់គ្រង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ។ |
| ២ | ០៤/០២/១៧<br>**ម៉ោង១៦:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីជួបជុំពិសាបាយសាមគ្គី និងទទួលភារកិច្ចថ្មី របស់សមាគមខ្មែរ-ចិន នៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ។ |
| ៣ | ០៧/០២/១៧<br>**ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៤/០២/១៧<br>**ម៉ោង១០:០០នាទី** | ទទួលសិទ្ធិពីរាជរដ្ឋាភិបាល ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការអនុវត្តគម្រោងសាងសង់អគារសន្តិសុខ នៃទីស្តីការគណៈរដ្ឋមន្ត្រី រវាងរាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម នៃសាធារណរដ្ឋប្រជាមានិតចិន នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១៤/០២/១៧<br>**ម៉ោង១៧:៣០នាទី** | ដឹកនាំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ចុះពិនិត្យ ស្លាកសញ្ញានៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ |
| ៦ | ១៥/០២/១៧<br>**ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីបើកជាផ្លូវការ "សន្និសីទស្តីពីធុរកិច្ចអន្តរជាតិនៅកម្ពុជាឆ្នាំ២០១៧" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារអាំងទែកង់ទីណង់តាល់។ |
| ៧ | ១៦/០២/១៧<br>**ម៉ោង១៥:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-គម្រោងវិនិយោគខ្សែបញ្ជូនអគ្គិសនី ២៣០គីឡូវ៉ុល ពីស្ថានីយវារីអគ្គិសនីស្ទឹងតាតៃមកភ្នំពេញ និងគម្រោងវិនិយោគបន្ថែមម៉ាស៊ីនផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព ១៣៥មេហ្គាវ៉ាត់ ខេត្តព្រះសីហនុ។<br>២-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១៧/០២/១៧<br>**ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-គម្រោងវិនិយោគខ្សែបញ្ជូនអគ្គិសនី ២៣០គីឡូវ៉ុល ពីស្ថានីយវារីអគ្គិសនីស្ទឹងតាតៃមកភ្នំពេញ និងគម្រោងវិនិយោគបន្ថែមម៉ាស៊ីនផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព១៣៥មេហ្គាវ៉ាត់ ខេត្តព្រះសីហនុ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| | | ២-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថានប័ននីតិប្បញ្ញត្តិលើ ”ពិធីសារទី៣ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ ក្នុងចំណោមរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ”។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៩ | **១៧/០២/១៧ ម៉ោង១៦:០០នាទី** | ដឹកនាំកិច្ចប្រជុំចង្អៀត នៃគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | **២១/០២/១៧ ម៉ោង០៨:៣០នាទី** | ចូលរួមជាកិត្តិយសក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៦ និងផែនការសកម្មភាពការងារឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១១ | **២២/០២/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិតជ័យលាភី ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ជូននិស្សិត សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (PPIU) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១២ | **២៣/០២/១៧ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំ០៦ នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | **២៣/០២/១៧ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែមករា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **២៤/០២/១៧ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំព្រៃកប្បាស នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅ ទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | **២៧/០២/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើក ពិធីអបអរសាទរទិវាជាតិ “ទីក្រុងស្អាតលើកទី៥ ឆ្នាំ២០១៧ អមជាមួយវេទិកាធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍លើកទី១ និងពិធីប្រគល់ជ័យលាភីចលនាប្រឡងប្រណាំង បដិសណ្ឋារកិច្ចល្អសេវាសាធារណៈរបស់ក្រុង-ខណ្ឌបេក្ខភាពលើកទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៦ | **២៨/០២/១៧ ម៉ោង០៨:៣០នាទី** | ចូលរួមកិច្ចប្រជុំពិភាក្សាលើការរៀបចំធនធានហិរញ្ញវត្ថុជួយគណៈកម្មាធិការគណបក្សឃុំ-សង្កាត់ និងបេក្ខជនពេញសិទ្ធិក្រុមប្រឹក្សាឃុំ-សង្កាត់ នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សន្ទរកថា

# ឯកឧត្តមទេសរដ្ឋមន្ត្រី យឹម ណុលឡា ទេសរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានគណៈកម្មការសម្របសម្រួលជាមួយភាគីចិន លើគម្រោងសាងសង់អគារសន្តិសុខនៃទីស្តីការគណៈរដ្ឋមន្ត្រី

### ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការអនុវត្តគម្រោងសាងសង់អគារសន្តិសុខនៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីសាធារណរដ្ឋប្រជាមានិតចិន នៅព្រឹក ថ្ងៃអង្គារ ទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី

- លោក **លី អាន** ទីប្រឹក្សាសេដ្ឋកិច្ចនិងពាណិជ្ជកម្មនៃស្ថានទូតសាធារណរដ្ឋប្រជាមានិតចិន នៅព្រះរាជាណាចក្រកម្ពុជា និងជាតំណាងទីភ្នាក់ងារសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ នៃក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន ជាទីគោរព
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីមេត្រី !




ថ្ងៃនេះជាទិវាមួយដ៏ឧត្តុងឧត្តមដែលរូបខ្ញុំផ្ទាល់មានកិត្តិយសដ៏ធំធេងដែលបានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចាត់រូបខ្ញុំជាតំណាងរាជរដ្ឋាភិបាល

កម្ពុជា ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការអនុវត្តគម្រោងសាងសង់អគារសន្តិសុខ នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីសាធារណរដ្ឋប្រជាមានិតចិន។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមថ្លែងអំណរគុណដ៏ជ្រៅលជ្រៅចំពោះ សម្តេចតេជោ **ហ៊ុន សែន** ដែលមានទំនុកចិត្តចំពោះរូបខ្ញុំ។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន និងប្រជាជនចិន ដែលតែងតែជួយដល់ប្រទេសកម្ពុជាលើគ្រប់វិស័យ។ ដោយឡែកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋាភិបាលចិនបានផ្តល់ជូននូវអគារមិត្តភាពដ៏ស្កឹមស្កៃ ដែលយើងកំពុងប្រារព្ធពិធីនេះ ព្រមទាំងអគាររដ្ឋបាលថ្មីនៅខាងក្រោយដែលទើបនឹងសាងសង់ចប់រយៈពេលជិតមួយឆ្នាំ ហើយនាពេលនេះគឺអគារសន្តិសុខមួយទៀតសម្រាប់កងអង្គរក្សស្ថិតនៅខាងលិច ដែលនឹងចាប់ផ្តើមសាងសង់នៅដើមត្រីមាសទី៤ ឆ្នាំ២០១៧នេះ។ អគារថ្មីនេះ នឹងមានសារៈសំខាន់ និងសម្រួលការងារច្រើនដល់កងអង្គរក្សដែលទទួលភារកិច្ចការពារទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រៅពីនោះ រដ្ឋាភិបាលចិនបានជួយព្រះរាជាណាចក្រកម្ពុជាលើគ្រប់វិស័យ ក្នុងនោះមានជាអាទិហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងស្ពាន ដែលបានរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ជាក់ស្តែងកាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៧ម្សិលមិញនេះរាជរដ្ឋាភិបាលកម្ពុជា បានសម្ពោធស្ពានកោះធំដែលសាងសង់ដោយសាធារណរដ្ឋប្រជាមានិតចិន។



ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រី
ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

គម្រោងអគារសន្តិសុខនៃទីស្តីការគណៈរដ្ឋមន្ត្រី រួមមានៈ

- ទីតាំងៈ ស្ថិតនៅខាងក្រោយអគារឧបសម្ព័ន្ធនៃទីស្តីការគណៈរដ្ឋមន្ត្រី
- ផ្ទៃក្រឡាដី ៩២៣,៤ម២ បណ្តោយ ៤៤,៦០ ម៉ែត្រ ទទឹង ១៨,៧៥ ម៉ែត្រ
-ផ្ទៃក្រឡាអគារ ១.៣៥០ម២ បណ្តោយ ៤៣.៩ ម៉ែត្រ និងទទឹង ៧.២ ម៉ែត្រ កម្ពស់ចំនួន ៤ជាន់ (រួមទាំងជាន់ផ្ទាល់ដី)

- អគារសន្តិសុខនៃទីស្តីការគណៈរដ្ឋមន្ត្រីនេះ សម្រាប់អង្គរក្សចំនួន ៨០នាក់
- ជាន់ផ្ទាល់ដី មានបន្ទប់ប្រជុំចំណុះ ៨០នាក់ អាហារដ្ឋាន ផ្ទះបាយ និងបន្ទប់ទឹករួម
-ជាន់ទី១ មានបន្ទប់មេបញ្ជាការ ការិយាល័យសម្រាប់១០នាក់ បន្ទប់ដាក់អាវុធ បន្ទប់អ្នកថែរក្សាអាវុធ បន្ទប់ស្នាក់ និងបន្ទប់ទឹករួម
- ជាន់ទី២ មានបន្ទប់ស្នាក់នៅចំនួន៩ ចំណុះ៣៦នាក់ និងបន្ទប់ទឹករួម
- ជាន់ទី៣ មានបន្ទប់ស្នាក់នៅចំនួន៩ ចំណុះ៣៦នាក់ និងបន្ទប់ទឹករួម

-មានបំពាក់នូវគ្រឿងសម្ភារៈមួយចំនួនដូចៈ គ្រែ/តុទូក្នុងបន្ទប់សម្រាក សម្ភារៈចាំបាច់សម្រាប់អាហារដ្ឋាននិងផ្ទះបាយ សម្ភារៈចាំបាច់សម្រាប់បន្ទប់មេបញ្ជាការ ការិយាល័យបន្ទប់ប្រជុំ (តុ កៅអី មីក្រូ ម៉ាស៊ីនត្រជាក់...)

-អគារសន្តិសុខនៃទីស្តីការគណៈរដ្ឋមន្ត្រីនេះ ត្រូវបានធ្វើការគូរប្លង់ដោយក្រុមហ៊ុន Hunan Provincial Architectural Design Institute ហើយអគារសន្តិសុខនៃទីស្តីការគណៈរដ្ឋមន្ត្រីនេះ នឹងចាប់ផ្តើមធ្វើការសាងសង់នៅក្នុងខែតុលា ឆ្នាំ២០១៧ ដែលមានរយៈពេលសាងសង់ចំនួន១៥ខែ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ឯកឧត្តម ឧត្តមសេនីយ៍ឯក **នោគ ចន្ថា** មេបញ្ជាការរងបញ្ជាការដ្ឋានអង្គរក្ស និងជាមេបញ្ជាការអង្គភាពការពារសន្តិសុខគោលដៅទីស្តីការគណៈរដ្ឋមន្ត្រី និងទីស្តីការនាយករដ្ឋមន្ត្រី

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមបញ្ជាក់ថារាជរដ្ឋាភិបាលកម្ពុជាអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយចិនតែមួយ។ ខ្ញុំសូមរំលឹកផងដែរថា មិត្តភាពកម្ពុជាចិនគឺមានតាំងពីយូរលង់ណាស់មកហើយ។ ហើយចំណងមិត្តភាពនេះបានពង្រឹងនឹងពង្រីកកាន់តែរឹងមាំនៅសម័យសម្តេចឪ ព្រះបរមរតនកោត **សម្តេចព្រះនរោត្តម សីហនុ** ជាមួយលោកប្រធានម៉ៅសេទុង និងលោកនាយករដ្ឋមន្ត្រីជូអេឡាយ។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ភ្លឺស្វាងនិងឆ្លៀសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានចាត់ទុកថា សាធារណរដ្ឋប្រជាមានិតចិនគឺជាមិត្តយុទ្ធសាស្រ្តគ្រប់ជ្រុងជ្រោយនឹងរឹងមាំជាមួយព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំក៏សូមកោតសរសើរចំពោះក្រុមការងារគណៈកម្មការសម្របសម្រួលជាមួយភាគីចិន លើគម្រោងសាងសង់អគារសន្តិសុខនៃទីស្តីការគណៈរដ្ឋមន្ត្រី ការិយាល័យសេដ្ឋកិច្ចនិងពាណិជ្ជកម្មនៃស្ថានទូតសាធារណរដ្ឋប្រជាមានិតចិននៅព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន Hunan Provincial Architectural Design Institute ដែលបានសហការយ៉ាងល្អប្រសើរលើការងារកន្លងមកធ្វើឲ្យការគូរប្លង់អគារសន្តិសុខ នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាអគារតំណាងឲ្យចំណងមិត្តភាពរវាងរដ្ឋាភិបាលកម្ពុជា-ចិន ទទួលបានលទ្ធផលល្អប្រសើរ។

នៅទីបញ្ចប់នេះ ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សូមប្រកបតែនឹងពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in